**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:១៧០
ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ ១៩៩៨
សាលដីកា
លេខ: ១៩៥
ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ................ជាចៅក្រម
៣-លោក ............... ជាចៅក្រម
៤-លោក ................. ជាចៅក្រម
៥-លោក ............. ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

-លោក .................

តំណាងមហាអយ្យការ

-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខសាលដីកា២៣៨ ចុះថ្ងៃទី២៥ខែឧសភា ឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៨២ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សណារភេទស្រីអាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះទីលំនៅផ្ទះលេខ ៣៥២ ផ្លូវជាតិលេខ ៥ក្រុមទី៤ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ឪពុកឈ្មោះសៀវ ជៀវ(រ) ម្តាយឈ្មោះ ស៊ីម ណៃ(រ) ប្តីឈ្មោះ ប៊ុន សួរ ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះសូ ជៀប ហៅម៉ាក់ ធូ ភេទស្រីអាយុ៥០ ឆ្នាំជាតិខ្មែរមុខរបរលក់ដូរ មានទីលំនៅផ្ទះលេខ ៤៥៤E1ផ្លូវម៉ៅសេទុងក្រុមទី៣ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ឪពុកឈ្មោះ សូ ភួន (ស) ម្តាយឈ្មោះ ទួន ធុន(ស) ប្តីឈ្មោះ ហែម សារ៉ន មានកូន៣នាក់ ។

**កម្មវត្ថុបណ្តឹង:** ប្តឹងទាមទារប្រាក់ចំនួន ១៣០៧០ដុល្លារអាមេរិក

បានឃើញបណ្តឹងសាទុក្ខលេខ ១១៤ ចុះថ្ងៃទី២៥ខែឧសភា ឆ្នាំ១៩៩៨ របស់ឈ្មោះ អ្នកស្រីសៀវ ណារី ប្តឹងមិនសុខប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿយដ្ឋប្បវេណីលេខ១៧០ ចុះថ្ងៃទី១០-០៦-៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០២-១០-៩៥ របស់ដើមចោទឈ្មោះសណារបញ្ជាក់ថាខ្លួនប្តឹងសុំទាមទារប្រាក់ជំពាក់ ១៣០៧០ដុល្លា ពីឈ្មោះសូ ជៀប ដោយហេតុថាឈ្មោះសូ ជៀប បានជំពាក់ប្រាក់ខ្លួនចំនួន១៣០៧០ដុល្លា ហើយ

មានកិច្ចសន្យាចុះថ្ងៃទី១៦ខែតុលា ឆ្នាំ១៩៩២ ហើយពុំព្រមគោរពតាមកិច្ចសន្យាគឺ ពុំព្រមសងខ្លួនសោះរហូតដល់សព្វថ្ងៃ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២៧ (ឃ) ចុះថ្ងៃទី០៧ខែសីហា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះសូ ជៀប ដែលមានតំណាងមេធាវីឈ្មោះខូវ ចន្ថា ចុះថ្ងៃទី ១៨_៨_៩៦ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- ទទួលលិខិតផ្ទេរសិទ្ធិរបស់ឈ្មោះសូ ជៀប ចុះថ្ងៃទី១៨_០៤-៩៦ ឱ្យទៅឈ្មោះខូវ ចន្ថា មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៥២(ក) ចុះថ្ងៃទី០៥-០៤-៩៦ ទុកជាបានការ តែកែប្រែចំណុចការប្រាក់គិតចាប់ពីថ្ងៃទី១២-១០-៩៣ វិញ តាមមាត្រាទី៥៨ នៃក្រិត្យច្បាប់លេខ៣៨ក្រ.ច ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨-១០-៨៨ ។

៤. សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទ តំណាងចុងចម្លើយមេធាវី ចុងចម្លើយ ចុងចម្លើយ សម្រាប់បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់២ខែ គិតចាប់តាំងពីពេលនេះតទៅ ។

បានឃើញសេចក្តីសុំប្តឹងតវ៉ាលេខ២៤(ឃ) ចុះថ្ងៃទី២៣-០៩-៩៧ របស់ឈ្មោះសូ ជៀប ប្តឹងមិនសុខចិត្តនឹងសេចក្តីវិនិច្ឆ័យរបស់តុលាការក្រុងភ្នំពេញទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីវេលខ២៣៨ ចុះថ្ងៃទី២៥-០៥-៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៣-០៩-៩៧ របស់ឈ្មោះសូ ជៀប ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរប្បវេណីលេខ២៧(ឃ) ចុះថ្ងៃទី០៧-០៨-៩៧ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣. ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០២_១០_៩៥ របសំឈ្មោះ សណរទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៤. កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្តឹងបានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង២៥៥០៖ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៖ ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និងលើអាជ្ញាធរតុលាការ៥.០០០រៀល សរុប ១៣.០០០រៀល និង បង្គាប់ឱ្យឈ្មោះ សណរបង់ពន្ធសមាមាត្រ ១% លើទឹកប្រាក់ចំនួន ១៣០៧០ដុល្លា ។

៥. សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ១១៤ ចុះថ្ងៃទី ២៥-០៥-៩៨ របស់អ្នកស្រី សណរប្ដឹងមិនសុខចិត្តនឹងសេចក្ដីសម្រេច របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិនិត្យលើសាលដីការដ្ឋប្បវេណីយខ ២៣៨ ចុះថ្ងៃទី ២៥-៥-៩៨ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្ដីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់និងគតិច្បាប់ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្ដាប់ទម្លើយរបស់ឈ្មោះសណរនៅពេលជំនុំជំរះថា: បានជាខ្លួនប្ដឹងសាទុក្ខ ព្រោះសាលាឧទ្ធរណ៍កាត់ក្ដីមិនយុត្តិធម៌ គ្មានពិចារណាលើភស្តុតាងឯកសារស្របច្បាប់ ហើយទទួលស្គាល់នូវ ចម្លើយបំពានការពិតគ្មានសច្ចៈ ។ ខ្លួនសូមឱ្យតុលាការកំពូល បដិសេធសាលដីកាលេខ ២៣៨ របស់សាលា ឧទ្ធរណ៍ចោល ។

បានស្ដាប់ចម្លើយរបស់ឈ្មោះសូ ជៀប នៅពេលជំនុំជំរះថា : តាមពិតលិខិតសរសេរ ធ្វើកោសល្យវិច្ច័យ ជាលិខិតខ្លែងក្លាយខ្លួនពុំទទួលស្គាល់ឡើយគឺ សៀវ ណារី ជាអ្នកប្រឌិតខ្លួនឯងហើយ សៀវ ណារី ជាអ្នកសរសេរ ខ្លួនសូមឱ្យតុលាការកំពូលតម្កល់សាលដីការបស់ សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសេចក្ដីសន្និដ្ឋានមេធាវីចុងចម្លើយថា : ខ្លួនសូមបញ្ជាក់ពីក្រដាសដែលតុលាការយកធ្វើជាសំអាងក្រដាសមួយដាក់ថា ម៉ាក់ ធូ ខ្វះ ចៃ ភិន ចំនួន១១០៧ដុល្លា ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩២ គ្មានស្នាមមេដៃ គ្មានហត្ថលេខា ។ ដូច្នេះបើពិនិត្យទៅលើអង្គច្បាប់ ខ្លួនសូមក្រុមប្រឹក្សាជំនុំជំរះពិចារណាទៅលើមាត្រា៤ និង មាត្រា ៥៧ នៃក្រិត្យច្បាប់លេខ៣៨ គ្រ.ច ។

ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយយការណ៍

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

ក្រោយពីបានស្ដាប់ចម្លើយដោះសារបស់គូភាគី និង សេចក្ដីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ

ក្រោយពីបានពិភាក្សត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ១១៤ ចុះថ្ងៃទី២៥-០៥-៩៨ របស់អ្នកស្រី សៀវ ណារី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការ ចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យអ្នកស្រី សូ ជៀប រួចខ្លួនពីបំណុលរបស់អ្នកស្រី សៀវ ណារី ដោយអាងហេតុថា លិខិតចុះថ្ងៃទី១២-១០-៩២ ដែលសរសេរថា: ម៉ាក់ ធូ ខ្វះចៃ ភីន ១៣.០៧០ ដុល្លាអាមេរិកពុំមានស្នាមមេដៃ ឬ ហត្ថលេខាពុំអាចយកជាការបាននោះ ជាការមិនត្រឹមត្រូវទេ ពីព្រោះថា ៖

ក.លិខិតនេះវាជាកំណត់ដៃដែលពាណិជ្ជករនិយមប្រើប្រាស់នៅតាមទីផ្សារហើយជាភស្តុតាងមួយសម្រាប់បំពេញបន្ថែមលើភស្តុតាងផ្សេងៗទៀត ឱ្យមានលក្ខណៈពេញលញដែលអាចយកជាការបាន ។

A ខ- na គ្មានភស្តុតាង ឬមូលហេតុណាផ្សេងទៀតដែលបញ្ជាក់ថា អ្នកស្រីសូ ជៀប សរសេរលិខិតជំពាក់ប្រាក់នេះ ឱ្យគេដោយពុំបានជំពាក់ប្រាក់តនោះទេ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចបដិសេធសាលក្រមរបស់ពុលាការក្រុងភ្នំពេញ ដោយអាង ហេតុថា អ្នកស្រីម៉ែន ហឿន ហៅភីន បានឆ្លើយថា លិខិតជំពាក់ប្រាក់ ចុះថ្ងៃទី ១២-១០-៩២ គឺឈ្មោះ សណារជាអ្នក សរសេរ ដែលធ្វើឱ្យលទ្ធផលកោសល្យវិច្ឆ័យពុំមានភាពត្រឹមត្រូវនោះ ក៏ជាការ ភ័ន្តច្រឡំដែរពីព្រោះថា ៖

ក.លិខិតជំពាក់ប្រាក់ធ្វើនៅឆ្នាំ១៩៩៦ ប៉ុន្តែតុលាការទើបតែសួរយកចម្លើយអ្នកស្រីម៉ែន ហឿន នៅឆ្នាំ១៩៩៦ ដូច្នេះចម្លើយតាមការចងចាំក្នុងរយៈពេលច្រើនឆ្នាំកន្លងមកហើយនោះ ប្រាកដជាអាចមានការភ័ន្តច្រឡំ ។

ខ-តាមគោលការណ៍ច្បាប់ ចម្លើយផ្ទាល់មាត់របស់សាក្សីពុំអាចនាំឱ្យមោឃៈភាពលិខិតជាលាយលក្ខណ៍អក្សរ បានទេ ដូច្នេះចម្លើយរបស់អ្នកស្រី ម៉ែន ហឿន ហៅភីន ពុំអាចនាំឲ្យមោឃៈភាពលិខិត ១៨/៩៧ ចុះថ្ងៃទី១៩-០៥-៩៧ របស់ការិយាល័យកោសល្យវិច្ឆ័យរបស់ក្រសួងមហាផ្ទៃ និងលិខិតលេខ០១២ ចុះថ្ងៃទី១៦-០៦-៩៧ របស់ការិយាល័យ បច្ចេកទេសវិទ្យាសាស្ត្រនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដែល បញ្ជាក់ថា លិខិតចុះថ្ងៃទី១២_១០_៩២ ពិត ជាសរសេរដោយអ្នកស្រី K សូ ជៀប ហៅ ម៉ាក់ ធូ បានឡើយ ។

- យល់ឃើញថា សាក្សីចំនួនបីនាក់គឺ អ្នកស្រី ម៉ែន ហឿន លោក ពុធ ធារី និង អ្នកស្រី ហេង សាមុ ដែលបាន ស្បថរួចហើយ សុទ្ធតែបានឆ្លើយថា អ្នកស្រី សូ ជៀប ពិតជាជំពាក់ ប្រាក់អ្នកស្រី សណារប្រាកដមែន តុលាការអាចយក ជាការបាន រីឯចម្លើយសាក្សី ២នាក់របស់អ្នកស្រី សូ ជៀប ដែលបានឆ្លើយថាៈ រឿងតុទីន ឮថាបានទូទាត់រួចអស់ហើយ ចំណែកជំពាក់ពីមុនឬក្រោយមកទៀតនោះ ខ្លួនមិនដឹងទេ តុលាការពុំអាចពិចារណាបានឡើយ ។

- យល់ឃើញថា ការដែលមេធាវីចុងចម្លើយលើកឡើង អំពីភាពមិនត្រឹមត្រូវនៃកិច្ចសន្យា នៃលទ្ធផលកោសល្យ វិច្ឆ័យ បដិកោសល្យវិច្ឆ័យ និងចម្លើយសាក្សីនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថាទំនាក់ទំនងអាជីវកម្ម( ទូទាត់ប្រចាំថ្ងៃ) តំណត់ដៃ របស់ភាគីអាចយកជាការបាន តាមទម្លាប់ដែលគេធ្វើ ឯកោសល្យវិច្ឆ័យរហូតដល់ បដិកោសល្យវិច្ឆ័យធ្វើតាម សំណូមពររបស់តុលាការនោះ គប្បីយកជាការបានហើយ ពីព្រោះជាលទ្ធផលនៃសមត្ថកិច្ចជំនាញ ។ ហើយអំពីការលើក ឡើងពីមាត្រា៤ និង៥៧ នៃក្រិត្យច្បាប់លេខ៣៨ក្រ.ច នោះជាការត្រឹមត្រូវសម្រាប់បែបបទនៃកិច្ចសន្យា ប៉ុន្តែការខ្វះ ខាតពុំបំពេញ តាមបែបបទជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់នេះ ពុំអាចនាំឱ្យមោឃៈភាពកិច្ចសន្យាឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២៣៨ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១- ទទួលបណ្តឹងសាទុក្ខលេខ១១៤ ចុះថ្ងៃទី២៥.០៥.៩៨ របស់អ្នកស្រី សណារទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។ របស់សាលាឧទ្ធរណ៍ទាំងមូល ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២៣៨ ចុះថ្ងៃទី២៥ខែឧសភាឆ្នាំ១៩៩៨របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៧០ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០៛ ដែលអ្នកស្រី សណារបានបង់រួចហើយគឺៈ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥០០០៛ សរុប១៩០០០៛ ហើយតម្រូវឲ្យអ្នកស្រី សូ ដៀប សងប្រាក់១៩០០០៛ នេះទៅអ្នកស្រី សណារវិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨ ។